ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៨១៥ សហវ.......

ថ្ងៃ ពុធ ៦រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២០

**ជម្រាបជូន**

**លោកឧកញ៉ាប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា**

**កម្មវត្ថុ:** អំពីការអនុញ្ញាតឱ្យនាំចេញអង្ករសឡើងវិញ។

**យោង:**- ចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ លើលិខិតលេខ ៣៨១២ សហវ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- លិខិតលេខ ០៥៣/២០ ស.អ.ក ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ របស់សហព័ន្ធស្រូវអង្ករកម្ពុជា
- លិខិតលេខ ២៣០០ សហវ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកឧកញ៉ាប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាជ្រាបថា តាមសំណើរបស់សហព័ន្ធស្រូវអង្ករកម្ពុជា រាជរដ្ឋាភិបាលសម្រេចផ្តល់ការអនុញ្ញាតឱ្យធ្វើការនាំចេញអង្ករសជាបណ្តើរៗឡើងវិញ តាមកិច្ចសន្យាបញ្ជាទិញពីក្រៅប្រទេស ដោយគិតចាប់ពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោកឧកញ៉ា** ជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

សូម **លោកឧកញ៉ា** ទទួលនូវការរាប់អានពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**

- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666